

Australian Aid | ASEAN-Australia Counter Trafficking

# សេរីភាពក្នុងការបំលាស់ទីសម្រាប់ជនរងគ្រោះដោយការជួញដូរ

## ច្បាប់ គោលនយោបាយ និង ការអនុវត្តក្នុងតំបន់អាស៊ាន

## អំពីអ្នកនិពន្ធ

ឯកសារព័ត៌មាននេះនិពន្ធដោយបណ្ឌិត Anne Gallagher និងបណ្ឌិត Marika McAdam។ ឯកសារនេះផ្អែកលើការសិក្សាឆ្នាំ ២០១៨ ស្តីពីការអនុវត្តទាក់ទងនឹងមណ្ឌលសំចត ដែលត្រូវបានធ្វើឡើងក្នុងតំបន់អាស៊ាន ក្រោមការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី។ ការសិក្សានាពេលនោះ បានទទួលមូលដ្ឋានព័ត៌មានពីការសិក្សាពីមុនមកក្នុងឆ្នាំ ២០១០។ សូមថ្លែងអំណរគុណដល់មន្ត្រី និងបុគ្គលិកគាំទ្រជនរងគ្រោះ ក្នុងបណ្តាប្រទេសអាស៊ានដែលបានចែករំលែកបទពិសោធន៍ និងទស្សនៈយល់ឃើញរបស់ខ្លួនដោយក្តីសប្បុរស។

*ឯកសារបោះពុម្ពផ្សាយនេះ ត្រូវបានឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈក្រសួងការបរទេស និងពាណិជ្ជកម្ម។ ទស្សនៈទាំងឡាយដែលបានបង្ហាញក្នុងឯកសារនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធសុទ្ធសាធ និងមិនតំណាងឲ្យទស្សនៈរបស់រដ្ឋាភិបាលអូស្ត្រាលីទេ។*

*កម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស ត្រូវបានគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី និងត្រូវបានអនុវត្តដោយក្រុមហ៊ុន ខាដណូ* (Cardno)។

# បញ្ហា

ក្នុងតំបន់អាស៊ានទាំងមូល ជនរងគ្រោះដោយការជួញដូរ ជារឿយៗ តែងធ្លាក់ខ្លួនទៅក្នុងទម្រង់មួយចំនួននៃការឃុំខ្លួន។ ឧទាហរណ៍ ជនរងគ្រោះបរទេសប្រហែលជាត្រូវជាប់ក្នុងមន្ទីរឃុំឃាំងអន្តោប្រវេសន៍ ជាពិសេសដោយសារពួកគេត្រូវបានកំណត់អត្តសញ្ញាណខុស ថាជាជនទេសន្តប្រវេសន៍គ្មានឯកសារត្រឹមត្រូវ។ ជនដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជន រងគ្រោះដោយការជួញដូរ ដែលត្រូវបានបញ្ជូន ត្រឡប់ទៅផ្ទះវិញ ក៏អាចត្រឡប់ទៅជាប់ឃុំក្នុងមន្ទីរឃុំឃាំងអន្តោប្រវេសន៍ផងដែរ ដោយសារគ្មានទីកន្លែងដទៃទៀតសម្រាប់ពួកគាត់។ ជនរងគ្រោះដោយការជួញដូរ អាចត្រូវគេឃុំខ្លួនដោយសារបានប្រព្រឹត្តសកម្មភាពឧក្រិដ្ឋពាក់ព័ន្ធនឹងការជួញដូរដែលបានកើតមានចំពោះខ្លួនគាត់៖ ឧទាហរណ៍ គាត់បានពាក់ព័ន្ធក្នុងមុខរបរខុសច្បាប់ដូចជាពេស្យាចារ ឬពាក់ព័ន្ធក្នុងអំពើខុសច្បាប់នានា ដូចជាការរត់ពន្ធគ្រឿងញៀន ឬការសុំទានជាដើម។

ម្យ៉ាងវិញទៀត ក្នុងប្រទេសមួយចំនួន ជនដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះដោយការជួញដូរ ត្រូវបានគេយកទៅទុកក្នុងមណ្ឌលសំចត ហើយនៅក្នុងមណ្ឌលសំចតនោះគេពុំអនុញ្ញាតឱ្យពួកគាត់អាចចាកចេញបានទេ ឬ ពួកគាត់មានសិទ្ធិសេរីភាពបំលាស់ទីក្នុងកម្រិតកំណត់យ៉ាងខ្លាំង (ឧទាហរណ៍ ការធ្វើដំណើរដោយមានអ្នកអម) អាស្រ័យទៅតាមឆន្ទានុសិទ្ធិរបស់បុគ្គលិកនៃមណ្ឌលសំចតនោះ។ ក្នុងស្ថានភាពបែបនេះ ជារឿយៗ ក៏មានការតម្រូវឱ្យជនរងគ្រោះលះបង់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដូចជាប្រាក់កាស ឯកសារ និងទូរស័ព្ទ ហើយថែមទាំងត្រូវស្ថិតនៅក្រោមវិធានជាច្រើនសន្ធឹកសន្ធាប់ ដែលត្រួតត្រាលើការប្រព្រឹត្តរបស់ពួកគេ ហើយថែមទាំងអាចមានការដាក់ពិន័យចំពោះពួកគេក្នុងករណីមិនគោរពតាមផងដែរ។ ទម្រង់នៃការឃុំខ្លួនបែបនេះ ដែលជាការផ្តោតយកចិត្តទុកដាក់នៃឯកសារព័ត៌មានរបស់យើងនេះ បង្កឱ្យមានសំណួរធ្ងន់ធ្ងរមួយចំនួនជុំវិញភាពស្របច្បាប់ ក៏ដូចជាភាពចាំបាច់ នៃការឃុំខ្លួនបែបនេះ។



Photographer: Airam Dato Foundation / Unsplash

## តើមណ្ឌលសំចតបិទទ្វារ ជាក់ស្ដែងគឺជា "ការឃុំឃាំង" ជនរងគ្រោះឬ?

អ្នកដែលបញ្ជាឱ្យយកជនរងគ្រោះទៅដាក់ក្នុងមណ្ឌលសំចត និងអ្នកជំរុញការអនុវត្តក្នុងការយកជនរងគ្រោះទៅដាក់ក្នុងមណ្ឌលសំចត កម្រចាត់ទុកថានេះជា "ការឃុំឃាំង" ជនរងគ្រោះណាស់។ ផ្ទុយទៅវិញ គេមើលឃើញថានេះគឺជាទម្រង់មួយនៃ "ការឃុំឃាំងបែបការពារ" ពីព្រោះគេចាត់ទុកគោលបំណងនៃការធ្វើបែបនេះថាជាឧត្តមប្រយោជន៍របស់ជនរងគ្រោះ។ ប៉ុន្តែ ច្បាប់អន្តរជាតិកំណត់និយមន័យការឃុំឃាំងយ៉ាងច្បាស់ថា "ជាការដកហូតសេរីភាពផ្ទាល់ខ្លួនលើកលែងតែជាលទ្ធផលនៃសាលក្រមសម្រេចចំពោះបទល្មើសណាមួយ" ស្ថាប័នអង្គការសហប្រជាជាតិទទួលបន្ទុកគោលការណ៍នៃកិច្ចការពារជនគ្រប់រូបក្រោមទម្រង់ណាមួយនៃការឃុំឃាំង ឬ ការដាក់ពន្ធនាគារ អនុម័តដោយសេចក្តីសម្រេចនៃកិច្ចប្រជុំពេញអង្គលេខ 43/173 ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ ១៩៨៨)។ ដោយហេតុនេះ ពាក្យថា "ការឃុំឃាំង" អាចគ្របដណ្តប់លើស្ថានភាពផ្សេងៗជាច្រើននៃការឃុំខ្លួនជនរងគ្រោះដោយការជួញដូរ មិនថានៅក្នុងពន្ធនាគារបន្ទប់ចាក់សោររបស់នគរបាល កន្លែងឃុំឃាំងអន្តោប្រវេសន៍ គ្រឹះស្ថានសុខុមាលភាពកុមារ មន្ទីរពេទ្យ ឬមណ្ឌលសំចតឡើយ។ វាគឺជាប្រការសំខាន់ណាស់ដែលត្រូវយល់ថា តើស្ថានភាពមួយគឺជាស្ថានភាព "ឃុំឃាំង" ឬទេ ពីព្រោះវិធានជាតិនិងអន្តរជាតិ កំណត់កាតព្វកិច្ចលើរដ្ឋ ទាក់ទិននឹងប្រការដែលថាតើពេលណាការឃុំឃាំងគឺជារឿងអាចទទួលយកបាន និងតើចាំបាច់ត្រូវមានវិធានការអ្វីខ្លះដើម្បីការពារសិទ្ធិរបស់ជនជាប់ឃុំ។





Photographer: Jo Aigner

# ការគេចខ្លួន

ក្នុងបរិបទនៃការជួញដូរមនុស្ស គេប្រើពាក្យ "ការគេចខ្លួន" ដើម្បីសំដៅលើស្ថានភាពដែលជនរងគ្រោះគេចខ្លួនរួចពីជនដែលបានជួញដូរពួកគេ។ ប៉ុន្តែ ក៏មានករណីជនរងគ្រោះប៉ុនប៉ងរត់គេចពីមណ្ឌលសំចតដែលគេយកពួកគាត់ទៅទុកផងដែរ បន្ទាប់ពីពួកគាត់បានគេចខ្លួនរួចពីជនដែលបានជួញដូរពួកគេ។ មណ្ឌលសំចតមួយចំនួនមានលក្ខណៈហ៊ុំព័ទ្ធដោយរបង មានសន្តិសុខយាម មានជញ្ជាំង និងរបងខ្ពស់ៗ មានទ្វារចាក់សោរ និងលួសបន្លា។ មណ្ឌលសំចតទាំងនោះអាចមានភូមិសាស្ត្រនៅដាច់ដោយឡែកពីគេ ហើយមានការរឹតបន្តឹងទំនាក់ទំនងជាមួយពិភពខាងក្រៅ តាមរយៈការរឹតបន្តឹង ឬឃ្លាំមើលលទ្ធភាពក្នុងការទទួលបានទូរស័ព្ទប្រើប្រាស់ការនិយាយទូរស័ព្ទនិងភ្ញៀវដែលចូលមកជួប។ជនរងគ្រោះដោយការជួញដូរមួយចំនួន បានព្យាយាមយ៉ាងខ្លាំងក្នុងការទាមទារសេរីភាពរបស់ខ្លួនមកវិញ តាមរយៈការប៉ុនប៉ងផ្តួលរំលំអំណាចបុគ្គលិកមណ្ឌលសំចត យកភ្លើងដុតទីតាំងនោះ ដោយសង្ឃឹមថាខ្លួនគាត់នឹងត្រូវគេបណ្តេញចេញ បង្កគ្រោះថ្នាក់ដល់ខ្លួនឯងដើម្បីជាថ្នូរឱ្យគេផ្ទេរទៅមន្ទីរពេទ្យ ប៉ុនប៉ងសុំជំនួយពីសាធារណៈជនដែលដើរឆ្លងកាត់ ឬថែមទាំងបង្ករបួសដល់ខ្លួនឯងនៅពេលព្យាយាមជម្នះលើរបាំងរូបវន្ត។ ឧទាហរណ៍ទាំងនេះ ជាការស្តែងឱ្យឃើញអំពីតថភាពជាក់ស្តែង ក៏ដូចជាគ្រោះថ្នាក់នៃការឃុំឃាំងនៅក្នុងមណ្ឌលសំចត។

## តើហេតុអ្វីបានជាមន្ត្រីរដ្ឋាភិបាល និងអ្នកដទៃទៀត យកជនរងគ្រោះ ដោយការជួញដូរទៅឃុំឃាំងក្នុងមណ្ឌលសំចត ?

មន្ត្រីរដ្ឋាភិបាល និងអ្នកដទៃទៀតផ្ដល់មូលហេតុដូចខាងក្រោម ថាជាមូលដ្ឋានហេតុផល នៃការយកជនរងគ្រោះដោយការជួញដូរជាមនុស្សពេញវ័យទៅឃុំឃាំងក្នុងមណ្ឌលសំចត៖

### ភាពចាំបាច់ត្រូវការពារជនរងគ្រោះ

> ជាញឹកញាប់ គេតែងផ្ដល់ហេតុផលថា ការឃុំឃាំងជនរងគ្រោះដោយការជួញដូរនៅក្នុងមណ្ឌលសំចត គឺជាវិធានការដើម្បីការពារពួកគាត់កុំឱ្យរងគ្រោះថ្នាក់បន្ថែមទៀត ជាពិសេស គ្រោះថ្នាក់បង្កឡើងដោយអ្នកដែលបានកេងប្រវ័ញ្ចពួកគាត់។ ភាពងាយរងគ្រោះរបស់ជនរងគ្រោះចំពោះការបំភិតបំភ័យនិងការសងសឹក ដោយអ្នកកេងប្រវ័ញ្ច ក៏ដូចជាភាពងាយរងគ្រោះចំពោះការត្រូវគេជួញដូរជាថ្មី គឺជាភាពងាយរងគ្រោះយ៉ាងពិតប្រាកដ។ ទោះយ៉ាងនេះក្ដី ក៏ការសម្រេចចិត្តយកជនរងគ្រោះទៅឃុំឃាំងក្នុងមណ្ឌលសំចតកម្រត្រូវបានធ្វើឡើងដោយផ្អែកលើការវាយតម្លៃបុគ្គលមួយដែលបង្ហាញឱ្យឃើញអំពីហានិភ័យដែលគួរឱ្យជឿជាក់បានណាស់។

### ដោយសារជនរងគ្រោះខ្វះឋានៈស្របច្បាប់

> ក្នុងប្រទេសមួយចំនួន ច្បាប់ពុំអនុញ្ញាតឱ្យជនរងគ្រោះដោយការជួញដូរដែលជាជនទេសន្តរប្រវេសន៍ ក្នុងស្ថានភាពមិនប្រក្រតីអាចស្នាក់នៅក្នុងប្រទេសនោះបានឡើយ ទោះបីជា ការស្នាក់នៅបណ្ដោះអាសន្នក្ដី។ ពេលខ្លះ គេបានប្រើប្រាស់ទិដ្ឋភាពដែលពួកគាត់បានបំពានច្បាប់អន្តោប្រវេសន៍ ជាមូលហេតុដើម្បីយកជនរងគ្រោះជាជនបរទេសទៅដាក់ក្នុងមណ្ឌលសំចតរបស់រដ្ឋាភិបាល ឬមណ្ឌលសំចតដែលបានទទួលការអនុម័តពីរដ្ឋាភិបាល។ បន្ថែមលើនេះ មានការលើកឡើងថា មណ្ឌលសំចតបិទទ្វារអាចជួយសម្របសម្រួលដល់ដំណើរការទ្វេភាគី (រួមទាំងការតាមរកគ្រួសារ និងការបញ្ជាក់សញ្ជាតិ) ដែលចាំបាច់ត្រូវធ្វើមុនពេលអាចធ្វើមាតុភូមិនិវត្តន៍ និងធ្វើសមាហរណកម្មជនរងគ្រោះត្រឡប់ទៅសហគមន៍ក្នុងប្រទេសកំណើតវិញ។

### តម្រូវការក្នុងការគាំទ្រជនរងគ្រោះ

> ពេលខ្លះ មានការលើកហេតុផលថា ការឃុំឃាំងនៅក្នុងមណ្ឌលសំចតគឺថាជាវិធីប្រសើរបំផុត ឬជាវិធីតែមួយគត់ ដើម្បីឆ្លើយតបចំពោះសេចក្ដីត្រូវការជំនួយបន្ទាន់របស់ជនរងគ្រោះ។ មានការអះអាងថា ប្រសិនបើមិនមានការបង្ខំឱ្យពួកគាត់ស្ថិតនៅក្នុងកន្លែងដែលមានការជួយគាំទ្រទាំងអស់នេះទេ ពួកគាត់នឹងមិនបានទទួលការគាំទ្រចាំបាច់ទាំងនេះឡើយ ពោលគឺ មានចាប់តាំងពីជំនួយផ្នែកវេជ្ជសាស្ត្រ រហូតដល់ដំបូន្មានផ្នែកច្បាប់។ ប្រទេសជាច្រើនមានសមត្ថភាពអាចជួយផ្ដល់ការគាំទ្រដល់ជនរងគ្រោះ ដោយពុំចាំបាច់ឃុំឃាំងពួកគាត់ឡើយ ហេតុនេះ វាគឺជាប្រការសំខាន់ណាស់ដែលត្រូវចោទសួរ ថាតើហេតុអ្វីបានជាគេចាត់ទុកថាអភិក្រមនេះមិនអាចធ្វើទៅរួច។

### ភាពចាំបាច់នៃការធានាថាជនរងគ្រោះអាចចូលរួមក្នុងការស៊ើបអង្កេត និងជំនុំជម្រះ

> ប្រសិនបើគ្មានសក្ខីកម្មពីជនរងគ្រោះទេ គេប្រហែលជាមានការលំបាក ឬមិនអាចធានាឱ្យមានការជំនុំជម្រះលើជនជួញដូរបានប្រកបដោយជោគជ័យឡើយ។ ប៉ុន្តែ ជារឿយៗ ជនរងគ្រោះមានមូលហេតុជម្រុញទឹកចិត្តតិចតួចប៉ុណ្ណោះ ដើម្បីសហការក្នុងដំណើរការនីតិវិធី ដោយជនរងគ្រោះជាច្រើនតែងតែចង់វិលត្រឡប់ទៅផ្ទះវិញ ឬទៅរកការងារប្រសើរជាងនេះ។ ដោយហេតុនេះ មានការលើកឡើងនូវហេតុផលចំនួនពីរក្នុងការឃុំឃាំងជនរងគ្រោះ៖ ទីមួយ ការឃុំឃាំងនេះអាចការពារជនរងគ្រោះពីការបំភិតបំភ័យកុំឱ្យសហការជាមួយអាជ្ញាធរ និងទីពីរ គឺជួយធានាថាពួកគាត់មានវត្តមានដើម្បីចូលរួមជាសាក្សីក្នុងសំណុំរឿងជួញដូរ។ ជារឿយៗ ដោយសារដំណើរការយុត្តិធម៌ព្រហ្មទណ្ឌមានរយៈពេលវែង ជនរងគ្រោះដែលជាសាក្សី អាចត្រូវជាប់ឃុំឃាំងអស់រយៈពេលជាច្រើនខែ ឬរហូតដល់ជាច្រើនឆ្នាំ (ក្រោមមូលហេតុនេះ) ដោយមានប្រាក់ចំណូលតិចតួច ឬមិនមានប្រាក់ ចំណូលទាល់តែសោះ និងដោយមានលទ្ធភាពតិចតួច ឬ មិនមានលទ្ធភាពទាល់តែសោះក្នុងការប្រាស្រ័យទាក់ទងជាមួយគ្រួសាររបស់ខ្លួន ហើយមិនមានការធានាថា ពួកគាត់នឹងទទួលបានអត្ថប្រយោជន៍ពីដំណើរការជំនុំជម្រះជនជួញដូរនោះឡើយ។

## តើការឃុំឃាំងជនរងគ្រោះជាមនុស្សពេញវ័យ សម្រេចបាននូវគោលបំណង នៃសកម្មភាពនេះ ឬទេ ?

ទោះបីជាអំណះអំណាងនីមួយៗ ដូចបានលើកឡើងខាងលើ អាចមានគុណតម្លៃក្នុងស្ថានភាពជាក់លាក់ក្តី ក៏អំណះអំណាងទាំងនេះមិនមានលក្ខណៈបញ្ចុះបញ្ចូលគួរឱ្យជឿជាក់ថាជាគោលនយោបាយដែលអាចអនុវត្តបានជាទូទៅឡើយ។ ជាក់ស្តែង មានការរកឃើញថា ក្នុងករណីមួយចំនួន លទ្ធផលដែលទទួលបាន គឺជាផលប៉ះពាល់បញ្ច្រាសពីចេតនានេះទាំងស្រុង។ ឧទាហរណ៍ ជំនួសឱ្យកិច្ចការពារជនរងគ្រោះ ការបង្ខាំងពួកគាត់ក្នុងមណ្ឌលសំចតបិទទ្វារអាចធ្វើឱ្យពួកគាត់កាន់តែមានភាពងាយរងគ្រោះចំពោះគ្រោះថ្នាក់ទៅវិញ ពោលគឺភាពងាយរងគ្រោះពាក់ព័ន្ធនឹងផ្លូវចិត្ត ដែលមិនបានធូរស្រាលជាងមុន ហាក់បីដូចជាបទពិសោធន៍កាលពីពេលពួកគាត់ត្រូវគេជួញដូរនោះដែរ។ ជំនួសឱ្យការសម្របសម្រួលដល់ការផ្តល់ការគាំទ្រ ការដាក់ជនរងគ្រោះក្នុងមណ្ឌលសំចតដោយផ្ទុយពីឆន្ទៈរបស់ពួកគាត់ អាចឈានទៅបដិសេធឱកាសឱ្យពួកគាត់អាចធូរស្បើយ និងបន្តដំណើររបស់ខ្លួនទៅមុខទៀតបាន។ ម្យ៉ាងទៀត ថ្វីបើ "ជនរងគ្រោះជាប់ឃុំ" ប្រហែលជាអាចមានលទ្ធភាពជួបអ្នកស៊ើបអង្កេត ឬព្រះរាជអាជ្ញាបានច្រើនក៏ដោយ ក៏ការបាត់បង់សេរីភាពអាចធ្វើឱ្យសក្ខីកម្មរបស់ពួកគេចុះខ្សោយ និងកាត់បន្ថយការសម្រេចចិត្ត និងឆន្ទៈរបស់ពួកគេក្នុងការសហការ។ ជាចុងក្រោយ វាគឺជាប្រការសំខាន់ដែលត្រូវកត់សម្គាល់ផលប៉ះពាល់លើបុគ្គលិកមណ្ឌលសំចតដែលធ្វើការគាំទ្រជនរងគ្រោះ ហើយត្រូវបានតម្រូវឱ្យបំពេញតួនាទីដូចជា "សន្តិសុខយាម" និងត្រូវទទួលខុសត្រូវចំពោះ "ការគេចខ្លួន"។

## តើច្បាប់ចែងដូចម្តេច ?

ថ្វីបើការអនុវត្តនេះនៅតែបន្តកើតមានក្តី ក៏ការឃុំឃាំងជនរងគ្រោះដោយការជួញដូរក្នុងមណ្ឌលសំចត និងគ្រឹះស្ថានដទៃទៀត គឺលែងសូវកើតមានជាទូទៅដូចពីមុនទៀតហើយ។ នេះជាការបង្ហាញឱ្យឃើញនូវការយល់ដឹងកាន់តែច្រើនឡើងថាអភិក្រមបែបនេះគឺពុំអនុលោមតាមសំណេរ និងស្មារតីនៃក្របខណ្ឌច្បាប់ ដែលត្រូវបានអភិវឌ្ឍឡើងជុំវិញបញ្ហាជួញដូរមនុស្សនោះទេ។ ឧទាហរណ៍ដ៏សំខាន់មួយ សូមមើលការដកស្រង់ចេញពីអនុសញ្ញាអាស៊ានស្តីពីការជួញដូរដូចខាងក្រោម ដែលហាមឃាត់យ៉ាងច្បាស់លាស់ ចំពោះការឃុំឃាំងជនដែលត្រូវបានគេជួញដូរ។

ប្រាកដណាស់ ការឃុំឃាំងជាប្រចាំគឺជាការបំពានគោលការណ៍ច្បាប់អន្តរជាតិមួយចំនួន (រួមទាំងសិទ្ធិទទួលបានសេរីភាពក្នុងការបំលាស់ទី និងការហាមឃាត់ការឃុំខ្លួនតាមទំនើងចិត្ត) និងគឺជាអំពើខុសច្បាប់ នៅពេលពុំមានមូលដ្ឋានហេតុផលជាក់លាក់ ទៅតាមបរិបទរបស់បុគ្គលនីមួយៗ។ សូមអានបន្ថែមក្នុងប្រអប់ខាងក្រោម។

## អនុសញ្ញាអាស៊ានស្តីពីការជួញដូរ

ភាគីនីមួយៗ មិនត្រូវឃាត់ឃាំងដោយមិនសមហេតុផលនូវជនទាំងឡាយណាដែលត្រូវបានកំណត់អត្តសញ្ញាណដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនថាជាជនរងគ្រោះដោយការជួញដូរ នៅក្នុងមន្ទីរឃុំឃាំង ឬពន្ធនាគារ នៅមុនពេល ក្នុងពេល ឬ ក្រោយពេលនៃដំណើរការនីតិវិធីរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាល សម្រាប់ការជួញដូរមនុស្សឡើយ។
មាត្រា ១៤(៨)



### តើការឃុំឃាំងជនរងគ្រោះក្លាយជាការរំលោភបំពានសិទ្ធិមនុស្សនៅពេលណា ?

ការឃុំឃាំងដែលមានហានិភ័យ ត្រូវបានកំណត់ថាជាការឃុំខ្លួនខុសច្បាប់ ឬការឃុំខ្លួនតាមទំនើងចិត្តកម្រិតខ្ពស់ ប្រសិនបើគេអាចបង្ហាញឱ្យឃើញថា ការឃុំឃាំងទាំងនោះឆ្លើយតបតាមលក្ខណៈវិនិច្ឆ័យមួយ ឬច្រើនដូចខាងក្រោម៖

- ការឃុំឃាំងពុំត្រូវបានចែងជាក់លាក់នៅក្នុងច្បាប់ ឬត្រូវបានកំណត់ធ្វើឡើងខុសនឹងច្បាប់
- ការឃុំឃាំងត្រូវបានផ្តល់ឱ្យ ឬកំណត់ធ្វើឡើងក្នុងលក្ខណៈរើសអើង (ឧទាហរណ៍ អនុវត្តតែចំពោះស្ត្រី និងកុមារី/កុមារ)
- ការឃុំឃាំងត្រូវបានកំណត់ធ្វើឡើងក្នុងរយៈពេលយូរមិនមានបញ្ជាក់រយៈពេលច្បាស់ ឬមានរយៈពេលមិនកំណត់
- ការឃុំឃាំងមានលក្ខណៈអយុត្តិធម៌ មិនមានលក្ខណៈអាចព្យាករណ៍បាន និង/ឬមានលក្ខណៈមិនសមមាត្រជាមួយបញ្ហា
- ការឃុំឃាំងពុំស្ថិតក្រោមការពិនិត្យឡើងវិញផ្នែកតុលាការ ឬផ្នែករដ្ឋបាល ដែលអាចបញ្ជាក់អះអាងអំពីភាពស្របច្បាប់នៃការឃុំឃាំងនោះ និងបន្តមានភាពចាំបាច់ម្រាប់ស្ថានភាពដែលអនុញ្ញាតឱ្យមានលទ្ធភាពដោះលែងក្នុងករណីមិនមានមូលដ្ឋានសម្រាប់ការឃុំខ្លួនជាបន្ត។

Photographer: Ario Adityo

ប្រភព៖ OHCHR សេចក្តីអត្ថាធិប្បាយចំពោះគោលការណ៍ និងគោលការណ៍ណែនាំស្តីពីការជួញដូររបស់អង្គការសហប្រជាជាតិទំព័រ ១៣៥-១៣៦ ។

## យេនឌ័រ និងការឃុំឃាំងក្នុងមណ្ឌលសំចត

ការអនុវត្តក្នុងតំបន់អាស៊ានចំពោះការឃុំឃាំងជនរងគ្រោះ មានលក្ខណៈយេនឌ័រក្នុងកម្រិតខ្ពស់។ ភាគច្រើនលើសលុបនៃជនរងគ្រោះដោយការជួញដូរ ដែលត្រូវបានឃុំឃាំងក្នុងមណ្ឌលសំចតគឺជាស្ត្រី។ ទិដ្ឋភាពនេះ អាស្រ័យមួយផ្នែកដោយសារស្ត្រី និងកុមារី ត្រូវបានចាត់ទុកថាជាអ្នកត្រូវការកិច្ចការពារដែលផ្តល់ដោយមណ្ឌលសំចតបិទទ្វារ។ មូលហេតុមួយទៀត គឺស្ត្រីនិងកុមារីច្រើនតែត្រូវបានកំណត់អត្តសញ្ញាណជាជនរងគ្រោះដោយការជួញដូរតាមរយៈបណ្តាញផ្លូវការ ជាហេតុធ្វើឱ្យពួកគេច្រើនតែមានលទ្ធភាពចូលមកក្នុងប្រព័ន្ធការពារផ្លូវការ និងមិនផ្លូវការ បើធៀបជាមួយបុរស និងកុមារា។ ជនរងគ្រោះជាបុរស ច្រើនតែត្រូវបានកំណត់អត្តសញ្ញាណខុសថាជាជនទេសន្តប្រវេសន៍ (ខុសច្បាប់) ដែលជាហេតុធ្វើឱ្យពួកគេត្រូវបានផ្ទេរទៅកាន់ស្ថាប័នឃុំខ្លួនអន្តោប្រវេសន៍ ហើយត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសកំណើតវិញនៅពេលក្រោយ។ ជាលទ្ធផល ពួកគេអាចពុំមានលទ្ធភាពទទួលបានសេវា និងការគាំទ្រដែលពួកគេមានសិទ្ធិទទួលបាន ក្នុងនាមជាជនរងគ្រោះដោយការជួញដូរ។ ថ្វីបើបណ្តាប្រទេសអាស៊ានមួយចំនួនបានបង្កើតមណ្ឌលសំចតសម្រាប់បុរសនិងកុមារាក្តី ក៏ចំនួនមណ្ឌលសំចតសម្រាប់ពួកគេ គឺមានចំនួនតិចជាងមណ្ឌលសំចតរបស់ស្ត្រីនិងកុមារីជាខ្លាំង ហើយតាមធម្មតាមណ្ឌលសំចតទាំងនោះតែងស្ថិតក្រោមវិធានខុសពីមណ្ឌលសំចតរបស់ស្ត្រីនិងកុមារី ពោលគឺ មណ្ឌលសំចតរបស់បុរសនិងកុមារាអនុញ្ញាតឱ្យមានសេរីភាពក្នុងការបំលាស់ទីច្រើនជាងមណ្ឌលសំចតរបស់ស្ត្រី និងកុមារី។ ច្បាប់អន្តរជាតិ និងច្បាប់តំបន់ ហាមឃាត់យ៉ាងច្បាស់ចំពោះការរើសអើង ក្រោមមូលដ្ឋាននៃភេទ។ ការអនុវត្តការឃុំឃាំងស្ត្រីនិងកុមារីជាប្រចាំ (និងការបដិសេធមិនផ្តល់កិច្ចការពារគ្រប់គ្រាន់ និងសេវាគាំទ្រសម្រាប់បុរសនិងកុមារា) មានលក្ខណៈជាការរើសអើងយ៉ាងជ្រាលជ្រៅ ហេតុនេះវាគឺជាការអនុវត្តខុសច្បាប់។

នៅពេលសេវាមណ្ឌលសំចត ពុំត្រូវបានកែសម្រួលឱ្យត្រូវទៅតាមសេចក្តីត្រូវការ ផលប្រយោជន៍ និងសម្បទារបស់បុគ្គល លទ្ធផលអាចធ្វើឱ្យមានការបង្ខំឲ្យប្រើប្រាស់និយាមយេនឌ័រលើមនុស្សដែលស្នាក់នៅក្នុងមណ្ឌលសំចតទាំងនោះ។ ក្នុងប្រទេសមួយ មានការកត់សម្គាល់ឃើញថាក្មេងស្រីវ័យជំទង់ ជារឿយៗ តែងទទួលបានជម្រើសធ្វើសកម្មភាពដែលរួមមាន កាត់ដេរ និងការអធិដ្ឋាន ហើយពុំបានផ្តល់ឱកាសដើម្បីលេងកីឡាទេ ចំណែកស្ត្រីពេញវ័យត្រូវបាន "ហាមឃាត់" មិនឱ្យជក់បារីដោយសារមានការរំពឹងទុកបែបបង្ខំ អំពីរបៀបដែលស្ត្រីគួរប្រព្រឹត្ត និងពុំគួរប្រព្រឹត្ត។

| អំណះអំណាង | ការសន្មត | កត្តាដែលជម្រុញការសន្មត | យុទ្ធសាស្ត្រដើម្បីជម្នះលើការសន្មត និងកាត់បន្ថយការឃុំខ្លួន |
|---|---|---|---|
| "ជនជួញដូរនឹងបង្កគ្រោះថ្នាក់ ឬ គំរាមកំហែងជនរងគ្រោះ" | › ជនរងគ្រោះដែលត្រូវបានអនុញ្ញាតឱ្យធ្វើការបំលាស់ទីដោយសេរី នឹងត្រូវរងរបួស ឬត្រូវគេសម្លាប់ ឬ ត្រូវបានបញ្ចុះបញ្ចូលមិនឱ្យផ្តល់សក្ខីកម្មប្រឆាំងនឹងជនជួញដូរ។<br>› ជនរងគ្រោះជាពិសេសស្ត្រី និងកុមារីត្រូវការមណ្ឌលសំចតសុវត្ថិភាព។ | › ករណីកើតហេតុ (ជាក់ស្តែង និងពាក្យចចាមអារាម) អំពីប្រការដែលជនជួញដូរបង្កគ្រោះថ្នាក់ ដល់ជនរងគ្រោះនៅក្រៅ មណ្ឌលសំចតជនរងគ្រោះស្ថិតក្នុងមណ្ឌលសំចតរងឥទ្ធិពលពីជនជួញដូរ ឬដៃជើងរបស់ជនជួញដូរ។ | › ស្ថាប័នជំរុញការអនុវត្តច្បាប់ និងបុគ្គលិករបស់មណ្ឌលសំចតត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយជនរងគ្រោះ ដើម្បីវាយតម្លៃ គ្រប់គ្រង និងកាត់បន្ថយហានិភ័យដែលគេយល់ថានឹងកើតមាន និងហានិភ័យជាក់លាក់។<br>› ស្ថាប័នជំរុញការអនុវត្តច្បាប់ និងបុគ្គលិកមណ្ឌលសំចតបានទទួលការបណ្តុះបណ្តាលក្នុងការធ្វើការវាយតម្លៃហានិភ័យ និងចូលរួមក្នុងការគ្រប់គ្រង/ការកាត់បន្ថយហានិភ័យ។ |
| "ជនរងគ្រោះចាំបាច់ត្រូវទទួលបានកិច្ចការពារពីខ្លួនឯង" | › ជនរងគ្រោះដែលត្រូវបានអនុញ្ញាតឱ្យធ្វើការបំលាស់ទីដោយសេរី នឹងធ្វើការសម្រេចចិត្តមិនបានល្អ៖ រត់ចេញ និងវិលទៅរកជនជួញដូរ និង/ឬការងារក្នុងទម្រង់ ឬក្នុងលក្ខខណ្ឌដែលពោរពេញដោយការកេងប្រវ័ញ្ច។ | › ករណីកើតហេតុ (ជាក់ស្តែង និងពាក្យចចាមអារាម) ស្តីពីប្រការដែលជនរងគ្រោះប៉ុនប៉ង "គេចខ្លួន" ពីមណ្ឌលសំចតបិទទ្វារ។<br>› មានការផ្តោតការយកចិត្តទុកដាក់ហួសប្រមាណលើជនរងគ្រោះជាស្ត្រី និងការកេងប្រវ័ញ្ចផ្លូវភេទ។<br>› និយាម និងការរំពឹងទុកផ្នែកយេនឌ័របែបបុរសនិយម និងបិតាធិបតេយ្យស្តីពីអ្វីដែលជាឧត្តមប្រយោជន៍របស់ជនរងគ្រោះ។ | › ទីភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ និងទីភ្នាក់ងារគាំទ្រជនរងគ្រោះ បញ្ជាក់អះអាង និងលើកកម្ពស់គោលការណ៍ដែលជនរងគ្រោះពុំអាចត្រូវបានជំនុំជម្រះ ឬដាក់ទណ្ឌកម្មចំពោះអំពើដែលបានប្រព្រឹត្តក្នុងគន្លងនៃការជួញដូរឡើយ។<br>› ទីភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ និងទីភ្នាក់ងារគាំទ្រជនរងគ្រោះ រួមទាំងបុគ្គលិកមណ្ឌលសំចត មានចំណេះដឹង និងសមត្ថភាពដើម្បីយល់អំពីចរន្តនៃការជួញដូរ និងទទួលស្គាល់សិទ្ធិរបស់ជនរងគ្រោះជាមនុស្សពេញវ័យក្នុងការសម្រេចចិត្តសម្រាប់ខ្លួនឯង ទោះបីជាការសម្រេចចិត្តមិនល្អក្តី។ |
| "សង្គមត្រូវការកិច្ចការពារពីជនរងគ្រោះដោយការជួញដូរ" | › ជនរងគ្រោះដែលអាចបំលាស់ទីដោយសេរី ច្បាស់ជានឹងបាត់ ខ្លួនទៅក្នុងសហគមន៍ ព្រមទាំងអាចចូលរួមពាក់ព័ន្ធក្នុងសកម្មភាពឧក្រិដ្ឋ និង/ឬសកម្មភាពមិនអើពើជាមួយសីលធម៌។ | › ការវិនិច្ឆ័យគុណតម្លៃបែបអត្តនោម័ត ជាពិសេស ការវិនិច្ឆ័យនិយាម និងការរំពឹងទុកផ្នែកយេនឌ័រ។<br>› ការច្របាច់បញ្ចូលគ្នារវាងរបៀបវារៈនៃការគ្រប់គ្រងទេសន្តរប្រវេសន៍ជាមួយការឆ្លើយតបទៅនឹងការជួញដូរ។ | › រៀបចំឱ្យមានរយៈពេលឆ្លុះបញ្ចាំង និងមធ្យោបាយដទៃទៀតដែលជនបរទេសអាចស្នាក់នៅ និងធ្វើការដោយស្របច្បាប់ បើទោះបីជាក្នុងរយៈពេលខ្លីក្តី។<br>› ប្រព័ន្ធគ្រប់គ្រងករណីសម្រាប់ជនរងគ្រោះនីមួយៗ បានទទួលការគាំទ្រពីសេវាតាមវិស័យសមស្រប ដោយមានបុគ្គលិកបានទទួលការបណ្តុះបណ្តាល និងបានទទួលការលើកទឹកចិត្ត ឱ្យធ្វើការជាមួយជនរងគ្រោះដោយការជួញដូរ។ ការយល់ដឹងដ៏រឹងមាំអំពីអភិក្រម ផ្តោតលើជនរងគ្រោះ និងអភិក្រមដែលគិតគូរដល់បញ្ហាយេនឌ័រ។ |

## បញ្ហាពិសេសនៃជនរងគ្រោះជាកុមារ

នៅពេលពិចារណាអំពីបញ្ហានៃការឃុំឃាំងក្នុងមណ្ឌលសំចត  វាគឺជាប្រការសំខាន់ដែលត្រូវទទួលស្គាល់ភាពខុសគ្នាជាមូលដ្ឋានមួយចំនួន រវាងជនរងគ្រោះដោយការជួញដូរជាកុមារ និងជនរងគ្រោះជាមនុស្សពេញវ័យ។ កុមារខ្វះទីភ្នាក់ងារច្បាប់ ហើយអាចងាយរងគ្រោះកាន់តែខ្លាំងទៅនឹងគ្រោះថ្នាក់នានា។ ការពិចារណាអំពីឧត្តមប្រយោជន៍របស់កុមារ  អាចនាំទៅដល់ការសម្រេចចិត្តដែលកុមារនោះគួរ  (ឬពុំគួរ) ត្រូវបានបង្ខាំងនៅក្នុងមណ្ឌលសំចត។ ច្បាប់ជុំវិញការឃុំឃាំងកុមារ មានភាពតឹងរឹងជាខ្លាំង ហើយវាគឺជាប្រការចាំបាច់ណាស់ដែលត្រូវគោរពតាមច្បាប់ទាំងនេះឱ្យបានខ្ជាប់ខ្ជួន ក្នុងករណីមានការសម្រេចចិត្តឱ្យយកកុមារទៅដាក់ក្នុងមណ្ឌលសំចត។ ប្រសិនបើមិនមានការប្រកាន់ខ្ជាប់តាមកាតព្វកិច្ច និងសិទ្ធិដូចមានចែងខាងក្រោមទេ នោះការឃុំឃាំងកុមារនឹងក្លាយជាអំពើខុសច្បាប់។

Photographer: Remi Yuan / Unsplash







## វិធានពាក់ព័ន្ធនឹងការឃុំឃាំងជនរងគ្រោះដោយការជួញដូរជាកុមារ

គណកម្មាធិការទទួលបន្ទុកសិទ្ធិកុមារបានសង្កត់ធ្ងន់ថា "ជាវិធានទូទៅ កុមារពុំគួរត្រូវបានដកហូតសេរីភាពឡើយ"។ (យោបល់ទូទៅលេខ ៦)។ អនុសញ្ញាស្តីពីសិទ្ធិកុមារ បកស្រាយបញ្ជាក់ថា រាល់ការឃុំឃាំងកុមារគួរតែជាវិធានការជាជម្រើសចុងក្រោយបំផុត និងសម្រាប់រយៈពេលសមស្របខ្លីបំផុត (មាត្រា ៣៧ (ខ))។ ហេតុនេះ រាល់ការសម្រេចចិត្តទាំងឡាយ ដែលត្រូវបានធ្វើឡើងទាក់ទងនឹងការឃុំឃាំងកុមារចាំបាច់ត្រូវតែជាឧត្តមប្រយោជន៍របស់កុមារ ហើយរាល់ការឃុំឃាំងចាំបាច់ត្រូវ៖

- អនុលោមតាមច្បាប់
- មិនធ្វើឡើងតាមទំនើងចិត្ត ហើយមិនមានការរើសអើង និង
- សម្រាប់រយៈពេលសមស្របខ្លីបំផុត

**កុមារដែលត្រូវបានឃុំឃាំង មានសិទ្ធិដូចខាងក្រោម៖**

- ត្រូវបានបំបែកពីមនុស្សពេញវ័យ លើកលែងតែត្រូវបានចាត់ទុកថាជាឧត្តមប្រយោជន៍របស់កុមារ ក្នុងការមិនត្រូវបានបំបែកចេញពីមនុស្សពេញវ័យ
- រក្សាទំនាក់ទំនងជាមួយគ្រួសាររបស់ខ្លួនតាមរយៈការឆ្លើយឆ្លង និងការសួរសុខទុក្ខ (លើកលែងតែក្នុងករណីពិសេសមួយចំនួនដូចជាការចូលរួមរបស់គ្រួសារក្នុងស្ថានភាពជួញដូរ)
- មានលទ្ធភាពទទួលបានជំនួយផ្នែកច្បាប់ និងជំនួយសមស្របដទៃទៀតភ្លាមៗ រួមទាំងការគាំទ្រឱ្យមានភាពធូរស្រាលឡើងវិញផ្លូវកាយ និងផ្លូវចិត្ត និង សមាហរណកម្មសង្គមទៅក្នុងបរិយាកាសដែលលើកកម្ពស់សុខភាព ការគោរពឱ្យតម្លៃខ្លួនឯង និងសេចក្ដីថ្លៃថ្នូរចំពោះកុមារ
- ជំទាស់ដោយ ចំពោះភាពស្របច្បាប់នៃការដកហូតសេរីភាពរបស់ខ្លួននៅចំពោះមុខតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចឯករាជ្យ និងអព្យាក្រឹត្យដទៃទៀត និងទទួលបានការសម្រេចចិត្តភ្លាមៗ។

Photographer: Cxxiohi / Unsplash

## លុបបំបាត់ការឃុំឃាំងក្នុងមណ្ឌលសំចត និងលើកកម្ពស់ស្ថានភាពរបស់ជនរងគ្រោះក្នុងមណ្ឌលសំចត៖ ឱកាស និងយុទ្ធសាស្ត្រ

អនុសញ្ញាអាស៊ាន ចែងយ៉ាងច្បាស់អំពីការប្ដេជ្ញាចិត្តរួមគ្នារបស់រដ្ឋសមាជិកអាស៊ានក្នុងការឆ្លើយតបចំពោះការជួញដូរ ដែលផ្ដែកលើសិទ្ធិ និងផ្ដោតយកចិត្តទុកដាក់លើជនរងគ្រោះ ក្នុងនោះរួមមានការជៀសវាងការឃុំឃាំងជនរងគ្រោះគ្រប់ពេលដែលអាចធ្វើបាន។ ខាងក្រោមនេះគឺជាឱកាស និងយុទ្ធសាស្ត្រដែលត្រូវបានស្នើឡើងដើម្បីជំរុញការប្ដេជ្ញាចិត្តរួមគ្នា ដូចបានពោលខាងដើម។

### ទទួលបានការយល់ព្រមជាលាយលក្ខណ៍អក្សរពីជនរងគ្រោះពេលពួកគាត់ចូលមកកាន់មណ្ឌលសំចត និងសុំការយល់ព្រមក្នុងចន្លោះរយៈពេលទៀងទាត់ បន្ទាប់ពីពេលនោះ៖

- ជនរងគ្រោះជាមនុស្សពេញវ័យទាំងអស់ គួរផ្ដល់ការយល់ព្រមច្បាស់លាស់ ចំពោះការចូលស្នាក់នៅក្នុងមណ្ឌលសំចត។ ការយល់ព្រមនោះគប្បីផ្អែកលើព័ត៌មានពេញលេញអំពីមូលហេតុដែលធ្វើឱ្យពួកគេចាំបាច់ត្រូវនៅក្នុងមណ្ឌលសំចត រយៈពេលដែលពួកគេត្រូវរំពឹងថាស្នាក់នៅទីនោះ និងលក្ខខណ្ឌនៃការស្នាក់នៅក្នុងមណ្ឌលសំចត។ ព័ត៌មាន "ពេញលេញ" មានន័យថាពុំគួរលាក់បាំងព័ត៌មានពាក់ព័ន្ធពីជនរងគ្រោះឡើយ រួមទាំងព័ត៌មានអំពីសិទ្ធិរបស់ពួកគាត់ផងដែរ។ គួរផ្ដល់ព័ត៌មានក្នុងលក្ខណៈដែលជនរងគ្រោះអាចយល់បាន ដោយគិតគូរដល់ភាសា អាយុ និងពិការភាពរបស់បុគ្គល។ ជនរងគ្រោះ អាចដកការយល់ព្រមរបស់ខ្លួនវិញបានទោះជានៅពេលណាក៏ដោយ ហើយអាជ្ញាធរមណ្ឌលសំចតចាំបាច់ត្រូវពិនិត្យឱ្យបានទៀងទាត់ ថាតើជនរងគ្រោះនៅតែបន្តយល់ព្រមស្នាក់នៅក្នុងមណ្ឌលសំចតទៀត ឬទេ។

### រក្សាកំណត់ត្រាសុក្រឹត្យ និងលម្អិតអំពីជនរងគ្រោះជាបុគ្គលនីមួយៗក្នុងមណ្ឌលសំចត៖

- គួរក្សាឱ្យមានកំណត់ត្រាលាយលក្ខណ៍អក្សរ ដើម្បីកត់ត្រាឱ្យបានសុក្រឹត្យអំពីការយល់ព្រមដំបូងរបស់ជនរងគ្រោះ ក្នុងការចូលមកស្នាក់នៅក្នុងមណ្ឌលសំចត ទ្រព្យសម្បត្តិអ្វីខ្លះដែលត្រូវបានរក្សាទុក ឬត្រូវបានដកហូត នៅពេលណា និងមូលហេតុអ្វី និងរាល់ការដកការយល់ព្រមរបស់ជនរងគ្រោះដែលលែងចង់បន្តស្នាក់នៅក្នុងមណ្ឌលសំចត មូលហេតុដែលត្រូវរក្សាទុកគាត់នៅក្នុងមណ្ឌលសំចត របៀប និងពេលវេលាដែលហេតុផលទាំងនោះត្រូវបានសម្រេចនិងសម្រេចដោយនរណា និងដោយរបៀបណា ពេលវេលា និងភាពញឹកញាប់នៃការសម្រេចចិត្តដែលត្រូវបានពន្យល់ទៅដល់ជនរងគ្រោះ និងធ្វើឡើងដោយនរណា។ កំណត់ត្រាទាំងនេះ គួរត្រូវបានរក្សាឱ្យមានសុវត្ថិភាពយោងទៅតាមច្បាប់ និងលក្ខខណ្ឌតម្រូវស្ដីពីកិច្ចការពារទិន្នន័យជាតិ។

## ផ្តល់ពេលវេលាឱ្យជនរងគ្រោះសម្រេចចិត្តអំពីអ្វីដែលពួកគាត់ចង់ធ្វើ៖

- ប្រទេសកាន់តែច្រើនកំពុងផ្តល់រយៈពេលសម្រាប់ការឆ្លុះបញ្ចាំង និងការស្តារឡើងវិញដល់ជនរងគ្រោះ ហើយក្នុងអំឡុងពេលនេះ ពួកគាត់បានទទួលកន្លែងស្នាក់នៅ និងការជួយគាំទ្រ ដែលនឹងជួយពួកគាត់ក្នុងការសម្រេចចិត្តអំពីជម្រើសរបស់ខ្លួន រួមទាំងថាតើពួកគាត់នឹងសហការជាមួយទីភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌក្នុងការជំនុំជម្រះជនដែលបានកេងប្រវ័ញ្ចពួកគាត់ឬទេ។ ដោយសារគោលបំណងនៃរយៈពេលសម្រាប់ការឆ្លុះបញ្ចាំង និងការស្តារឡើងវិញនេះ គឺដើម្បីធ្វើឱ្យជនរងគ្រោះមានអារម្មណ៍ថាមានសុវត្ថិភាព

## អនុវត្តដំណើរការសមស្របឱ្យបានម៉ឺងម៉ាត់ចំពោះការសម្រេចចិត្តពាក់ព័ន្ធនឹងមណ្ឌលសំចត៖

- រាល់ការសម្រេចចិត្តឃុំឃាំងជនរងគ្រោះដោយការជួញដូរ ចាំបាច់ត្រូវធ្វើឡើងដោយឈរលើមូលដ្ឋានច្បាប់ ដោយពុំមានលក្ខណៈរើសអើងណាមួយឡើយ។ ការសម្រេច ចាំបាច់ត្រូវធ្វើឡើងសម្រាប់បុគ្គលនីមួយៗ ពុំមែនយកទៅអនុវត្តក្នុងលក្ខណៈជាប្រចាំ ឬ ជាក្រុមនោះឡើយ។ ក្នុងករណីមិនមានកិច្ចដំណើរការសមស្របបែបនេះនៅឡើយ គួររៀបចំឱ្យមានកិច្ចដំណើរការបែបនេះ ហើយអ្នកធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធចាំបាច់ត្រូវដឹងអំពីកិច្ចដំណើរការនេះ។

## ផ្តាច់ការផ្សារភ្ជាប់គោលបំណងផ្នែកយុត្តិធម៌ព្រហ្មទណ្ឌចេញពីការសម្រេចចិត្តទាក់ទងនឹងមណ្ឌលសំចតរបស់ជនរងគ្រោះ៖

- ត្រូវពិចារណារកវិធីដើម្បីបានទទួលបានសេចក្តីថ្លែង និងសក្ខីកម្មពីជនរងគ្រោះដែលផ្តល់នូវភស្តុតាង ដោយពុំត្រូវឃុំឃាំងពួកគេរយៈពេលយូរក្នុងមណ្ឌលសំចត។ អ្នកប្រកបវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ គួរជ្រួតជ្រាបអំពីឱកាសដែលមានក្នុងច្បាប់នីតិវិធីព្រហ្មទណ្ឌ រួមទាំងការប្រើប្រាស់សក្ខីកម្មក្នុងអង្គបុរេជំនុំជម្រះ ការថតវីដេអូសក្ខីកម្ម ឬការផ្តល់សក្ខីកម្មតាមរយៈការតភ្ជាប់វីដេអូ។ ប្រសិនបើនៅពុំទាន់មានច្បាប់ទាំងនេះនៅឡើយ នីតិករគប្បីពិចារណាបង្កើតច្បាប់សម្រាប់ជម្រើសទាំងនេះ។ គប្បីរៀបចំឱ្យមានយន្តការដើម្បីធានាឱ្យបានថាជនរងគ្រោះទទួលបានព័ត៌មានអំពីវឌ្ឍនភាពនៃសំណុំរឿងដែលពួកគេចូលរួមពាក់ព័ន្ធ ហើយអាចស្នើសុំព័ត៌មាននៅពេលណាក៏បាន។

## ពន្លឿនកិច្ចដំណើរការនៃករណីជួញដូរដើម្បីកាត់បន្ថយបន្ទុកលើជនរងគ្រោះស្ថិតនៅក្នុងមណ្ឌលសំចត៖

- ប្រទេសមួយចំនួន បានខិតខំកាត់បន្ថយរយៈពេលស្នាក់នៅក្នុងមណ្ឌលសំចតបិទទ្វាររបស់ជនរងគ្រោះ តាមរយៈការប្រើប្រាស់តុលាការពិសេស ហើយចៅក្រម និងព្រះរាជអាជ្ញាបានទទួលការបណ្តុះបណ្តាលពិសេស ដើម្បីពន្លឿនសំណុំរឿងជួញដូរ។ គេអាចរៀនសូត្រពីមេរៀននៃកិច្ចខិតខំទាំងនេះ និងតាមរយៈការបញ្ជ្រាបការយល់ដឹងដល់អ្នកស៊ើបអង្កេត ព្រះរាជអាជ្ញា និងចៅក្រម អំពីផលប៉ះពាល់ដ៏អាក្រក់ ដែលអាចមានលើជនរងគ្រោះស្ថិតនៅក្នុងមណ្ឌលសំចតបណ្តាលមកពីការពន្យារពេល ។

## ដាក់ឱ្យមានគោលនយោបាយគ្រប់គ្រងមណ្ឌលសំចត ដែលកាត់បន្ថយបន្ទុកលើបុគ្គលិកមណ្ឌលសំចត៖

- តួនាទីចម្បងរបស់បុគ្គលិកមណ្ឌលសំចត ដែលជារឿយៗគឺជាបុគ្គលិកសង្គមកិច្ច គឺផ្ដល់ការគាំទ្រដល់ជនរងគ្រោះ។ ការទុកចិត្ត និងភាពស្និទ្ធស្នាល ដែលបុគ្គលិកត្រូវស្ថាបនាឱ្យមានជាមួយជនរងគ្រោះ ត្រូវបានបន្ទុចបង្អាក់ នៅពេលពួកគេត្រូវបានតម្រូវឱ្យជំរុញការរឹតបន្តឹងលើបំលាស់ទី។ លើសពីនេះ តួនាទី "ឃ្លាំមើល" ដូចជានគរបាល បានដាក់បន្ទុកមិនសមហេតុផលមកលើបុគ្គលិក ហើយអាចធ្វើឱ្យពួកគេត្រូវប្រឈមនឹងហានិភ័យគ្រោះថ្នាក់ជាសក្ដានុពល។ គួរពិនិត្យឡើងវិញ និងកែសម្រួលគោលនយោបាយមណ្ឌលសំចត ដើម្បីការពារបុគ្គលិកសង្គមកិច្ចរបស់មណ្ឌលសំចត កុំឱ្យធ្វើសកម្មភាពប្រឆាំងផលប្រយោជន៍របស់ជនរងគ្រោះ និងត្រូវបកស្រាយបញ្ជាក់ឱ្យច្បាស់ថា តួនាទីរបស់ពួកគេ គឺផ្ដល់ការគាំទ្រដល់ជនរងគ្រោះ។

## ស្វែងរកជម្រើសដទៃក្រៅពីមណ្ឌលសំចត តាមរយៈការថែទាំនៅតាមសហគមន៍៖

- ក្នុងករណីដែលអាចធ្វើបាន ជនរងគ្រោះគួរមានឱកាសទទួលបានការថែទាំនៅក្រៅប្រព័ន្ធមណ្ឌលសំចត។ អ្នកផ្ដល់សេវា គប្បីស្វែងរកវិធីដើម្បីផ្ដល់កន្លែងស្នាក់នៅឱ្យជនរងគ្រោះក្នុងកន្លែងស្នាក់នៅមានសុវត្ថិភាព និងសមស្រប រួមទាំងនៅក្នុងផ្ទះជួល ឬនៅក្នុងអាផាតមិន។ ឧបសគ្គទាំងឡាយដែលជនរងគ្រោះអាចជួបប្រទះក្នុងការស្វែងរកសេវាជំនួយក្នុងសហគមន៍ គប្បីត្រូវបានកំណត់ និងដោះស្រាយ។

## ការតែងតាំងអាណាព្យាបាលសម្រាប់ជនរងគ្រោះជាកុមារទាំងអស់៖

- ជនរងគ្រោះដោយការជួញដូរជាកុមារទាំងអស់ (ឬអ្នកដែលត្រូវបានសន្មតថាជាជនរងគ្រោះជាកុមារ) គប្បីទទួលបានការតែងតាំងឱ្យមានអ្នកអាណាព្យាបាលភ្លាមៗ ដែលមានសមត្ថភាព និងមានទទួលការបណ្ដុះបណ្ដាលត្រឹមត្រូវ ដែលត្រូវទទួលខុសចំពោះកិច្ចការពារឧត្តមប្រយោជន៍របស់កុមារនោះ។ ប្រសិនបើកុមារត្រូវបានឃុំឃាំងក្នុងមណ្ឌលសំចត អ្នកអាណាព្យាបាល (ដែលគប្បីជាបុគ្គលឯករាជ្យ និងអព្យាក្រឹត្យ ដែលត្រូវបានតែងតាំងដោយអាជ្ញាធរជាតិមានសមត្ថកិច្ច) ទទួលខុសត្រូវធានាថា ការឃុំឃាំងនោះគឺជា (និងបន្តជា) ឧត្តមប្រយោជន៍របស់កុមារហើយសិទ្ធិតាមនីតិវិធី និងសិទ្ធិពាក់ព័ន្ធដទៃទៀតត្រូវបានគោរពយ៉ាងពេញលេញ។

## បំបែកគោលបំណងគ្រប់គ្រងទេសន្តប្រវេសន៍ពីការសម្រេចចិត្តពាក់ព័ន្ធនឹងមណ្ឌលសំចត៖

- ដើម្បីធានាបានថាជនរងគ្រោះដោយការជួញដូរជាជនបរទេសពុំក្លាយជាកម្មវត្ថុនៃការឃុំឃាំងពាក់ព័ន្ធជាមួយអន្តោប្រវេសន៍ គួរដាក់ឱ្យមាន និងផ្ដល់ការអនុញ្ញាតឱ្យស្នាក់នៅបណ្ដោះអាសន្នសម្រាប់ជនរងគ្រោះដែលមានលក្ខណៈសម្បត្តិទទួលបានដោយពុំមានការពន្យារពេល ឬកិច្ចដំណើរការបែបការិយាល័យធិបតេយ្យមិនសមស្រប។

## វិនិយោគលើសេវាគាំទ្រជនរងគ្រោះ ដែលលើកកម្ពស់ជម្រើសជំនួសឱ្យការឃុំខ្លួនក្នុងមណ្ឌលសំចត៖

- អ្នកពាក់ព័ន្ធជារដ្ឋ មិនមែនរដ្ឋ និងអ្នកពាក់ព័ន្ធដទៃទៀត ដែលធ្វើជាដៃគូ និង/ឬផ្ដល់មូលនិធិដល់មណ្ឌលសំចត គប្បីផ្ដល់អាទិភាពចំពោះអ្នកផ្ដល់សេវាទាំងឡាយណា ដែលលើកកម្ពស់គម្រូនៃការផ្ដល់មណ្ឌលសំចតតាមសហគមន៍ និងការផ្ដល់មណ្ឌលសំចតបែបបើកទូលាយសម្រាប់ការថែទាំជនរងគ្រោះ។ ម្ចាស់ជំនួយ និងអ្នកដទៃទៀត ត្រូវទទួលខុសត្រូវធានាយ៉ាងណាឱ្យសកម្មភាពរបស់ខ្លួនមិនចូលរួមលើកទឹកចិត្តឱ្យមានការឃុំខ្លួនក្នុងមណ្ឌលសំចត ទោះជាតាមវិធីណាមួយក៏ដោយ។